ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

លេខ ៦១ "ព" ក្រ៧

ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤

សំណុំរឿងព្រហ្មទណ្ឌលេខ ២១៨៥

ចុះថ្ងៃ២២ ខែមេសា ឆ្នាំ២០២៣

សំណុំរឿងស៊ើបសួរលេខ ១៦២៦

ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣

សំណុំរឿងជំនុំជម្រះលេខ ២២៤៨

ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នាថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង១៤ និង៣០ នាទី រសៀល សាលសវនាការទី៧ ដោយមានសមាសភាព៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោកចៅក្រម [redacted] ជាប្រធានក្រុមប្រឹក្សា

លោកចៅក្រម ជាចៅក្រមប្រឹក្សា

លោកចៅក្រម ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ២១៨៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] រ៉ូនី ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរអ៊ីស្លាម មុខរបរមិនពិតប្រាកដ ឪពុកឈ្មោះ [redacted] ហ៊ីម "រស់" ម្តាយឈ្មោះ [redacted] ជា "រស់" នៅលីវ ជានីតិជន។(ក្នុងឃុំ)

ទីកន្លែងកំណើតនៅ [redacted] ខេត្តកណ្តាល។

មានទីលំនៅមុនពេលឃាត់ខ្លួននៅ [redacted] ខេត្តកណ្តាល។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

បច្ចុប្បន្នឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ម១) តាមដីការបង្គាប់ឱ្យឃុំខ្លួនលេខ ៣២៥៣ "ម" ដ.ឃ.ដ ចុះថ្ងៃទី២៤ មេសា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

ជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោសដោយសារមានការកាត់អវយវៈ ឬពិការភាព ប្រព្រឹត្តនៅចំណុចផ្ទះលេខ១៤៦B ផ្លូវ១០០៣ ក្រុមទី៧ ភូមិឡូកំបោរ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៨ នៃក្រមព្រហ្មទណ្ឌ។

២.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ន ភេទប្រុស អាយុ៥១ឆ្នាំ ជនជាតិខ្មែរអ៊ីស្លាម មុខរបរលក់ដូរ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ [redacted] រាជធានីភ្នំពេញ។



Scanned with CamScanner

៣.ជនរងគ្រោះឈ្មោះ [redacted] លីហ៊ាង ភេទប្រុស កើតថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៩ ទីកន្លែងកំណើតនៅ ភូ[redacted] រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្ន ក្រុមទី៧ ភូមិ[redacted] រាជធានីភ្នំពេញ។

៤.សាក្សីឈ្មោះ [redacted] ស្រីអូន ភេទស្រី កើតថ្ងៃទី០១ ខែមករា ឆ្នាំ១៩៨២ មុខរបរនៅផ្ទះ កម្រិតវប្បធម៌ថ្នាក់ទី១២ ទីកន្លែងកំណើត [redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ន ផ្ទះលេ[redacted] រាជធានីភ្នំពេញ។

៥.សាក្សីឈ្មោះ [redacted] ធារិន ភេទស្រី កើតថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨៦ មុខរបរនៅផ្ទះ កម្រិតវប្បធម៌ថ្នាក់ទី១ ទីកន្លែងកំណើត [redacted] រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្ន [redacted] ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

៦.សាក្សីឈ្មោះ [redacted] គឹម ភេទប្រុស កើតឆ្នាំ១៩៨៨ កម្រិតវប្បធម៌ថ្នាក់ទី២ ទីកន្លែងកំណើត [redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្ន ផ្ទះជួល ផ្លូវបេតុង ក្រុមទី៧ ភូមិឡកំបោរ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

៧.កញ្ញា [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

៨.លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង១២ និង៣០នាទី នៅត្រង់ចំណុចផ្ទះលេខ១៤៦B ផ្លូវ១០០៣ ក្រុមទី៧ ភូមិឡកំបោរ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មានករណី **លួចមានស្ថានទម្ងន់ទោសដោយសារមានការកាត់អវយវៈ ឬពិការភាព** បានកើតឡើង ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] រ៉ូនី ភេទប្រុស អាយុ១៩ឆ្នាំ។ មុនពេលកើតហេតុជនរងគ្រោះឈ្មោះ [redacted] លីហ៊ាង ភេទប្រុស អាយុ១៣ឆ្នាំ កំពុងលក់ដូរនៅចំណុចកើតហេតុខាងលើ បានដាក់ទូរស័ព្ទដៃចំនួន ០៣គ្រឿង ម៉ាកអាយហ្វូន ម៉ាកOPPO និងម៉ាកសាមសុង បញ្ចូលថ្មនៅលើតុ ហើយជនជាប់ចោទឈ្មោះ [redacted] រ៉ូនី ធ្វើជាចូលទៅទិញស្រាបៀរួចបន្លំលួចយកទូរស័ព្ទតែម្តង។ ភ្លាមនោះជនរងគ្រោះឃើញទាន់ក៏បានស្រែកភោរឡោរ ហើយដេញចាប់ជនជាប់ចោទ ពេលនោះជនជាប់ចោទបានរើសកាំបិតប៉ុងតោដែលនៅលើតុកាប់ជនរងគ្រោះត្រូវចំដៃខាងឆ្វេងបណ្ដាលឱ្យដាច់ម្រាមដៃនាង និងរបួសធ្ងន់ ទើបឆ្លើយដល់គ្រួសារជនរងគ្រោះ បានឃាត់ខ្លួនជនជាប់ចោទប្រគល់ជូនសមត្ថកិច្ចប៉ុស្តិ៍នគរបាលស្វាយប៉ាក ដើម្បីធ្វើការសួរនាំ និងបញ្ជូនជនជាប់ចោទមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញចាត់ការតាមនីតិវិធី។

-បានឃើញ របាយការណ៍សំយោគលេខ ០៦៣/២៣ រ.ប.ក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២០៤៥ អ.យ.ខ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៣។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២៧៣០ "ម" ដ.ង ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣។

-បានឃើញ ឯកសារភស្តុតាងនានានៅក្នុងសំណុំរឿង។

**នាពេលសវនាការ**

១.ជនជាប់ចោទឈ្មោះ [redacted] រ៉ូនី បានឆ្លើយសារភាពថា កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង១២ និង៣០នាទី ខ្លួនបានជិះម៉ូតូ១គ្រឿង ម៉ាកហុងដាសេ១២៥ ពណ៌ខ្មៅ ពាក់ផ្លាកលេខ កំពង់ចាម 1F-៥០១៦ ជិះចេញពីម្តុំផ្លូវប្រឡាយ ក្នុងសង្កាត់ស្វាយប៉ាក លុះខ្លួនជិះមកដល់កន្លែងកើតហេតុ បានឃើញបុរសម្នាក់កំពុងតែលក់ដូរម្នាក់ឯង ពេល



Scanned with CamScanner

នោះខ្លួនបានឃើញទូរស័ព្ទដៃចំនួន០៣គ្រឿង ដោយឃើញឱកាសស្ងាត់ល្អ ខ្លួនបានចូលទៅធ្វើជាទិញស្រាបៀរ ពេលនោះបុរសម្នាក់ជាអ្នកលក់ទៅយកស្រាបៀរ ខ្លួនបានធ្វើសកម្មភាពលួចយកទូរស័ព្ទដៃទាំង៣គ្រឿង បានសម្រេចបម្រុងគេចខ្លួន ស្រាប់តែជនរងគ្រោះឃើញ ក៏ស្រែកថាចោរៗ ជនរងគ្រោះនិងខ្លួនបានប្រតាយប្រតប់គ្នា ភ្លាមនោះខ្លួនបានឃើញកាំបិតប៉័ងតោនៅលើតុ ខ្លួនបានយកកាប់ទៅលើជនរងគ្រោះត្រូវចំដៃឆ្វេង និងក្បាល ភ្លាមនោះមានអ្នកជិតខាងចូលមកជួយ និងឃាត់រូបខ្លួនប្រគល់ឱ្យសមត្ថកិច្ចតែម្តង។

២.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មិន បានឆ្លើយថា មុនពេលកើតហេតុកូនប្រុសរបស់ខ្លួនឈ្មោះ [redacted] លីហ៊ាង កំពុងតែលក់ដូរនៅក្នុងផ្ទះ និងបានដាក់ទូរស័ព្ទ០៣គ្រឿងបញ្ចូលថ្ម ពេលនោះមានជនជាប់ចោទបានជិះម៉ូតូមកធ្វើជាទិញរបស់របរហើយបន្លំលួចទូរស័ព្ទដៃចំនួន០៣គ្រឿងបានសម្រេច ភ្លាមនោះកូនប្រុសរបស់ខ្លួនបានឃើញទាន់ ក៏បានប្រតាយប្រតប់គ្នា ហើយជនជាប់ចោទឈ្មោះ [redacted] វុទ្ធី បានប្រើប្រាស់កាំបិតប៉័ងតោកាប់ទៅលើជនរងគ្រោះដែលជាកូនប្រុសរបស់ខ្លួនឈ្មោះ [redacted] លីហ៊ាង ភេទប្រុស អាយុ១៣ឆ្នាំ បណ្តាលឱ្យដាច់ម្រាមដៃនាង និងរងរបួសក្បាលចំនួន០៣កន្លែង និងនៅលើមុខ រួចខ្លួនបានបញ្ជូនកូនទៅមន្ទីពេទ្យឯកជននៅម្តុំគល់ស្ពានលីយ៉ុងផាត់ត្រូវចំណាយអស់ប្រាក់ចំនួន ៥០០(ប្រាំរយ) ដុល្លារអាមេរិក ប៉ុន្តែបច្ចុប្បន្នខ្លួនបាននាំកូនមកព្យាបាលនៅមន្ទីពេទ្យរដ្ឋវិញ ដោយមិនទាន់ដឹងថាត្រូវចំណាយប្រាក់អស់ប៉ុន្មាននោះទេ។ ខ្លួនសំណូមពរសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ និងទាមទារសំណងចំនួន១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក។

៣.ក្រឡាបញ្ជីអានអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] លីហ៊ាង បានឆ្លើយថា កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោងប្រហែល១២ ថ្ងៃត្រង់ ខ្លួនកំពុងលក់ដូរឥវ៉ាន់នៅក្នុងផ្ទះ ដោយពេលនោះគ្រួសារខ្លួនបានចេញទៅក្រៅអស់ ពេលនោះខ្លួននៅផ្ទះតែម្នាក់ឯង មានបុរសម្នាក់មិនស្គាល់ឈ្មោះ អាយុប្រហែល២០ឆ្នាំ ជិះម៉ូតូ១គ្រឿង មិនស្គាល់ម៉ាក់ មកប្រាប់ខ្លួនថាទិញស្រាបៀរចំនួន៣កេស ក្រោយមកខ្លួនបានទៅយកស្រាបៀរឱ្យគាត់ ដោយមានការសង្ស័យខ្លួនបានសង្កេតមើល ឃើញជនជាប់ចោទធ្វើសកម្មភាពលួចយកទូរស័ព្ទដៃចំនួន៣គ្រឿង ពេលនោះខ្លួនបានរត់ទៅចាប់ជនជាប់ចោទ ហើយស្រែថាចោរៗ ជនជាប់ចោទបានរុញខ្លួនចេញនិងបានយកកាំបិទប៉័ងតោ កាប់មកលើខ្លួនត្រូវចំក្បាល និងដាច់ម្រាមដៃនាងខាងឆ្វេង ដេរចំនួន៣៤ថ្នេរ ភ្លាមនោះមានអ្នកជិតខាងបានចូលមកជួយចាប់ជនជាប់ចោទប្រគល់ឱ្យសមត្ថកិច្ចតែម្តង។

៤.សាក្សីឈ្មោះ [redacted] ស្រីអូន បានឆ្លើយថា មុនពេលកើតហេតុ ខ្លួនកម្រាកនៅក្នុងផ្ទះ មានអ្នកជិតខាងបានទូរស័ព្ទមកប្រាប់ថា មានចោរចូលប្លន់នៅផ្ទះរបស់ក្មួយឈ្មោះ ឆេង លីហ៊ាង និងបានកាប់ដាច់ម្រាបដៃ និងរបួសក្បាល ភ្លាមនោះខ្លួនបានជិះម៉ូតូចេញទៅមើលដល់ផ្ទះក្មួយ ពេលទៅដល់មិនឃើញនោះទេ ដោយសារមានអ្នកជិតខាងជួយបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យ បន្ទាប់មកខ្លួនបានទៅមើលដល់មន្ទីរពេទ្យ។

៥.សាក្សីឈ្មោះ [redacted] ធារិន បានឆ្លើយថា មុនពេលកើតហេតុខ្លួនកំពុងអង្គុយលេងទូរស័ព្ទនៅក្នុងផ្ទះ បានឮសម្លេងរបស់ឈ្មោះ [redacted] លីហ៊ាង ស្រែកនៅខាងក្រៅ ខ្លួនបានឃើញឈ្មោះ [redacted] លីហ៊ាង ឈាមហូរប្រឡាក់ពេញខ្លួន និងមានដាច់ម្រាមដៃ របួសត្រង់ថ្ងាស របួសខាងក្រោយក្បាល ចំណែកជនជាប់ចោទត្រូវបានអ្នកជិតខាងចាប់បាន ភ្លាមនោះខ្លួនបានជូនឈ្មោះ ឆេង លីហ៊ាង ទៅព្យាបាលនៅមន្ទីរពេទ្យតែម្តង។

៦.សាក្សីឈ្មោះ [redacted] ធីម បានឆ្លើយថា មុនពេលកើតហេតុខ្លួនកំពុងរើសជ័រអេតចាយ ដាក់ក្នុងបេនៅក្នុងផ្ទះ ខ្លួនបានឮសម្លេងស្រែកខ្លាំងៗថាអួយៗ ចេញពីផ្ទះជាប់គ្នា ពេលនោះខ្លួនបានដើរចេញទៅក្រៅ ឃើញជនជាប់ចោទកាន់កាប់



Scanned with CamScanner

បិតប៉ុងតោហក់ឡើងលើម៉ូតូ ខ្លួនបានស្ទុះទៅចាប់ជាប់កន្ទុះម៉ូតូផ្ដួល ភ្លាមនោះមានអ្នកជិតខាងមកជួយចាប់ជនជាប់ចោទ ប្រគល់ឱ្យសមត្ថកិច្ចតែម្ដង។

## សេចក្ដីសន្និដ្ឋានថ្លែងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា ក្រោយពីបានស្ដាប់ការពិភាក្សាដេញដោល អំណានចម្លើយនាពេលសវនាការ និងបានពិនិត្យភស្តុតាងក្នុងសំណុំរឿងរួចឃើញថា ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី បានឆ្លើយសារភាពថាខ្លួនពិតជាបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោសដោយសារមានកាត់អវយវៈ ឬពិការភាព ហេតុដូច្នេះ តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ២០៤៥ អ.យ.ខ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៣ ទុកនៅដដែល និងសុំឱ្យតុលាការពិចារណាសម្រេចផ្ដន្ទាទោសជនជាប់ចោទទៅតាមច្បាប់។

## សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-កញ្ញា [redacted] បានធ្វើសេចក្ដីសន្និដ្ឋានថា កូនក្ដីរបស់ខ្លួនបានចូលទៅលួចទូរស័ព្ទរបស់ជនរងគ្រោះប្រាកដមែន កូនក្ដីរបស់ខ្លួនបានឆ្លើយថា ជនរងគ្រោះបានយកកាំបិតកាប់មកលើកូនក្ដីរបស់ខ្លួនមុន ទើបកូនក្ដីរបស់ខ្លួនប្រតាយប្រតប់គ្នាបណ្ដាលឱ្យជនរងគ្រោះរបួសម្រាមដៃធ្ងន់ធ្ងរបែបនេះ ហើយកូនក្ដីរបស់ខ្លួនបានឆ្លើយសារភាពជូនតុលាការអស់ហើយ ហេតុនេះស្នើសុំក្រុមប្រឹក្សាជំនុំជម្រះផ្ដល់ស្ថានសម្រាលទោសឱ្យកូនក្ដីរបស់ខ្លួនផង។

-លោក [redacted] បានធ្វើសេចក្ដីសន្និដ្ឋានថា កាលពីយប់ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង១២ និង៣០នាទី កូនក្ដីរបស់ខ្លួនឈ្មោះ [redacted] វុទ្ធី បានជិះម៉ូតូមួយគ្រឿង ម៉ាក ហុងដាសេ១២៥ ពណ៌ខ្មៅ ពាក់ផ្លាកលេខ កំពង់ចាម ១F-៥០១៦ ដោយជិះចេញពីម្ដុំប្រឡាយក្នុងសង្កាត់ស្វាយប៉ាក ពេលជិះដល់ចំណុចកើតហេតុ កូនក្ដីរបស់ខ្លួនឈ្មោះ [redacted] វុទ្ធី ឃើញបុរសម្នាក់កំពុងលក់ដូរម្នាក់ឯង ពេលនោះកូនក្ដីរបស់ខ្លួនឃើញមានទូរស័ព្ទដៃចំនួនបីគ្រឿង និងមានឱកាសល្អបានចូលទៅទិញស្រាបៀរ ហើយពេលអ្នកលក់កំពុងតែទៅយកស្រាបៀរ កូនក្ដីរបស់ខ្លួនបានចូលទៅលួចទូរស័ព្ទដៃបីគ្រឿងនោះ ប៉ុន្តែរៀបនឹងចេញមកអ្នកលក់ឃើញក៏ស្រែកថាចោរៗ បណ្ដាលឱ្យមានការគោឡាឡើង ពេលនោះជនរងគ្រោះបានចាប់កូនក្ដីខ្លួនជាប់និងបានប្រតាយប្រតប់គ្នា កូនក្ដីរបស់ខ្លួនឈ្មោះ [redacted] វុទ្ធី បានទាញកាំបិតកាប់ទៅលើជនរងគ្រោះត្រូវចំដៃឆ្វេងនិងក្បាល ពេលនោះអ្នកជិតខាងចូលមកជួយចាប់បានកូនក្ដីរបស់ខ្លួនឈ្មោះ [redacted] វុទ្ធី។

ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣៥៣ អំពើលួច គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។

មាត្រា៣៥៦ អំពើលួចត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ០៦(ប្រាំមួយ)ខែ ទៅ ០៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀល ទៅ ៦.០០០.០០០(ប្រាំមួយ)រៀល។

មាត្រា៣៥៧ អំពើលួចត្រូវដាក់ពន្ធនាគារពី ០៣(បី)ឆ្នាំ ទៅ ១០(ដប់)ឆ្នាំ ក្នុងករណីអំពើលួចនេះ ប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬក្រោយពេលប្រើអំពើហិង្សា ប្រព្រឹត្តដោយការកាប់គាស់ទម្លុះទម្លាយ។

យោងតាមចម្លើយដែលកូនក្ដីរបស់ខ្លួនបានផ្ដល់ជូន ទាំងនៅក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ ដំណាក់កាលស៊ើបសួរ កូនក្ដីរបស់ខ្លួនបានផ្ដល់ចម្លើយប្រហាក់ប្រហែលគ្នា និងសារភាពពីអំពើល្មើសរបស់ខ្លួន។ លើសពីនេះទៅទៀតកូនក្ដីរបស់ខ្លួនឈ្មោះ [redacted] វុទ្ធី បច្ចុប្បន្នអាយុ១៩ឆ្នាំ រៀនសូត្របានតិចតួច ហើយមានមុខរបរមិនពិតប្រាកដ។ យោងតាមស្ថានភាពនេះ កូនក្ដីរបស់ខ្លួននៅវ័យក្មេង ខ្វះការចេះដឹង និងមិនបានពិចារណាអំពីផលវិបាកនៃសកម្មភាពល្មើសរបស់ខ្លួន ទើបឈានទៅដល់ការប្រព្រឹត្តអំពើនេះ។ មិនតែប៉ុណ្ណោះកូនក្ដីរបស់ខ្លួនរូបនេះ ទើបប្រព្រឹត្តអំពើនេះលើកទី១ ដោយសារភាពល្ងង់ខ្លៅខ្វះការពិចារណា ដូចនេះគប្បីតុលាការសម្រាលទោសដល់កូនក្ដីខ្លួនផង។



Scanned with CamScanner

យោងតាមអង្គហេតុ និងអង្គច្បាប់ ភស្តុតាង និងការអះអាងខាងលើនេះ ខ្លួនអាចសន្និដ្ឋាន កូនក្តីរបស់ខ្លួនបាន សារភាពជូនតុលាការអស់ហើយ ព្រមទាំងបានទទួលស្គាល់កំហុស ព្រមទាំងសន្យាថានឹងលែងប្រព្រឹត្តបទល្មើសទៀតហើយ។ កូនក្តីរបស់ខ្លួនជាជនដែលមានចំណេះដឹងទាប និងទើបតែបានប្រព្រឹត្តបទល្មើសលើកទី១ប៉ុណ្ណោះ។

ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រ៉ូនី សូមណូមពរតុលាការមេត្តាពិចារណាបន្ធូរបន្ថយផ្តន្ទាទោសចំពោះកូនក្តីខ្លួនដោយក្តីអនុគ្រោះ។

**សម្តីចុងក្រោយរបស់ជនជាប់ចោទ**

-ឈ្មោះ [redacted] រ៉ូនី ស្នើសុំតុលាការមេត្តាបន្ធូរបន្ថយទោសឱ្យខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹង។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ។

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី។

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា។

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

**សំអាងហេតុ**

ក.តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២៧៣០ "ម" ដ.ដ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនទៅជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ២១៨៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទឈ្មោះ [redacted] រ៉ូនី ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរអ៊ីស្លាម ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារមានការកាត់អវយវៈ** ឬពិការភាព ប្រព្រឹត្តនៅចំណុចផ្ទះលេខ១៤៦B ផ្លូវ១០០៣ ក្រុមទី៧ ភូមិឡូកំបោរ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ បទល្មើសដែលមានបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៨ នៃក្រមព្រហ្មទណ្ឌ មកជំនុំជម្រះ។

ខ.អង្គហេតុកើតឡើងនៅចំណុច ផ្ទះលេខ១៤៦B ផ្លូវ១០០៣ ក្រុមទី៧ ភូមិឡូកំបោរ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ហេតុនេះជាសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌនៃសាលាដំបូងរាជធានីភ្នំពេញ។

គ.អង្គហេតុកើតឡើងកាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ បើគិតរហូតមកដល់ពេលនេះ មិនទាន់ផុតអាជ្ញាយុកាលនៃបទល្មើសនោះទេ។

ឃ.តាមរបាយការណ៍សំយោគលេខ ០៦៣/២៣ រ.ប.ក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានធ្វើសេចក្តីសន្និដ្ឋានថា កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ នៅចំណុចផ្ទះលេខ១៤៦B ផ្លូវលេខ១០០៣ ក្រុមទី៧ ភូមិឡូកំបោរ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ [redacted] រ៉ូនី ពិតជាបានប្រព្រឹត្តអំពើ **លួចមានស្ថានទម្ងន់ទោសដោយសារមានការកាត់អវយវៈ** ឬពិការភាព ប្រាកដមែន។



Scanned with CamScanner

ង.តាមចម្លើយរបស់ដើមបណ្តឹង ចម្លើយរបស់ជនរងគ្រោះ ចម្លើយរបស់សាក្សី ព្រមទាំងភស្តុតាងផ្សេងៗទៀត មានភាពស៊ីសង្វាក់គ្នាបង្ហាញឱ្យតុលាការជឿបានថា ជនជាប់ចោទឈ្មោះ [redacted] រ៉ូនី ពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន។

ច.អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] រ៉ូនី ដែលបានប្រើកាំបិតប៉័ងតោកាប់ទៅលើជនរងគ្រោះឈ្មោះ ឆេង លីហ៊ាង ត្រូវចំដៃឆ្វេងបណ្តាលឱ្យដាច់ម្រាមដៃនាង និងរងរបួសធ្ងន់ បើផ្អែកតាមធាតុនីត្យានុកូលស្របទៅនឹងបទ **លួចមានស្ថានទម្ងន់ទោសដោយសារមានការកាត់អវយវៈ ឬពិការភាព** ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៨ នៃក្រមព្រហ្មទណ្ឌ។

មាត្រា៣៥៣ នៃក្រមព្រហ្មទណ្ឌ បានចែងថា អំពើលួច គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។

មាត្រា៣៥៨ នៃក្រមព្រហ្មទណ្ឌ បានចែងថា អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០(ដប់)ឆ្នាំ ទៅ ២០(ម្ភៃ)ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តមុនពេល ក្នុងពេល ឬ ក្រោយពេលប្រើហិង្សាដែលនាំឱ្យមានការកាត់អវយវៈ ឬពិការភាពជាអចិន្ត្រៃយ៍។

**ឆ.**អំពើដែលជនជាប់ចោទ បានប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ជាពិសេសធ្វើឱ្យប៉ះពាល់ដល់បូរណភាពរូបកាយរបស់ជនរងគ្រោះផ្ទាល់ ជាអំពើដែលច្បាប់ហាមឃាត់ និងតម្រូវឱ្យផ្តន្ទាទោស។

ជ.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ិន បានសុំទាមទារសំណងចំនួន ១៥.០០០(មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ហេតុនេះគប្បីតុលាការលើកយកករណីសំណងរដ្ឋប្បវេណីមកធ្វើការពិចារណា។

ឈ.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា សុំរក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ២០៤៥ អ.យ.ខ ចុះថ្ងៃទី២៣០១ ខែមិថុនា ឆ្នាំ២០២៣ ទុកជាបានការដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ការស្នើសុំនេះតុលាការនឹងលើកយកមកពិចារណា។

ញ.កំណត់ហេតុទទួលវត្ថុចាប់យក(១) លេខ៨៥៥ រ.វ.ត ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ មានកាំបិតប៉័ងតោ ដងឈើចំនួន០១ ជាវត្ថុតាងនៃការប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេចរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ ទូរស័ព្ទដៃម៉ាក VIVO ចំនួន០១គ្រឿង ទូរស័ព្ទដៃម៉ាក SAMSUNG ចំនួន០១គ្រឿង និងម៉ូតូម៉ាកHONDA C125 ចំនួន០១គ្រឿង (មិនប្រក្រតី) គប្បីតុលាការសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ។

ឋ.មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] រ៉ូនី ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរអ៊ីស្លាម ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារមានការកាត់អវយវៈ ឬពិការភាព** ប្រព្រឹត្តនៅចំណុចផ្ទះលេខ១៤៦B ផ្លូវ១០០៣ ក្រុមទី៧ ភូមិឡកំបោរ សង្កាត់ស្វាយប៉ាក ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា៣៥៨ នៃក្រមព្រហ្មទណ្ឌ។

**ហេតុដូច្នេះសម្រេច**

១.ផ្តន្ទាទោសលើឈ្មោះ [redacted] រ៉ូនី ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរអ៊ីស្លាម (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ១៣(ដប់បី)ឆ្នាំ ពីបទ **លួចមានស្ថានទម្ងន់ទោសដោយសារមានការកាត់អវយវៈ ឬពិការភាព** ប្រព្រឹត្តនៅចំណុចផ្ទះលេខ១៤៦B ផ្លូវ១០០៣ ក្រុមទី៧ ភូមិឡកំបោរ សង្កាត់ស្វាយប៉ាក ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ



Scanned with CamScanner

កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៨ នៃក្រមព្រហ្មទណ្ឌ។

២.វត្ថុចាប់យកដូចមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យក(១) លេខ ៨៥៥ រ.វ.ត ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣ មាន៖

-កាំបិតប៉ុងតោ ដងឈើចំនួន០១ ត្រូវរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ។

-ម៉ូតូម៉ាក HONDA C125 ចំនួន០១គ្រឿង (មិនប្រក្រតី) ទូរស័ព្ទដៃម៉ាក VIVO ចំនួន០១គ្រឿង និងទូរស័ព្ទដៃម៉ាកSAMSUNG ចំនួន០១គ្រឿង ត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ។

៣.បង្គាប់ឱ្យឈ្មោះ [redacted] រ៉ូនី ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរអ៊ីស្លាម (មានអត្តសញ្ញាណដូចខាងលើ) សងសំណងចំនួន ១០.០០០.០០០(ដប់លាន)រៀល ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ម៉ន ការទាមទារលើសពីនេះច្រានចោល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់បានកំណត់។

| | | | |
|---|---|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ១៣កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner